**NEWS RELEASE**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# លោកហ្សេអ៊ីដ ស្វាគមន៍យ៉ាងកក់ក្ដៅចំពោះការជ្រើសតាំងប្រធានសិទ្ធិមនុស្សថ្មី របស់ អ.ស.ប

ទីក្រុងហ្សឺណែវ (១០ សីហា ២០១៨) កាលពីថ្ងៃសុក្រ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស លោក ហ្សេអ៊ីដ រ៉ាអាដ អាល់ ហ៊ូសសេន បានស្វាគមន៍យ៉ាងកក់ក្ដៅចំពោះការជ្រើសតាំង លោកស្រី មីស្សែល បាស្សេឡេ (Michelle Bachelet) ដែលធ្វើឡើងដោយមហាសន្និបាត អ.ស.ប ដើម្បីឲ្យស្នងតំណែងបន្តពីលោក នៅពេលអាណត្តិរបស់លោកនឹងបញ្ចប់នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៨ នេះ។

លោក ហ្សេអ៊ីដ បានមានប្រសាសន៍ថា "ខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយចំពោះការតែងតាំង លោកស្រី មីស្សែល បាស្សេឡេ (Michelle Bachelet) ជាឧត្តមស្នងការថ្មីរបស់ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សថ្មី។ លោកស្រីមានគុណសម្បត្តិគ្រប់សព្វទាំងអស់ ដូចជា ភាពក្លាហាន ការតាំងចិត្តខ្ពស់ បំណងប្រាថ្នា និងឆន្ទៈមុះមុត ចំពោះសិទ្ធិមនុស្ស ដែលនឹងធ្វើឲ្យអ្នកស្រីក្លាយជាឧត្តមស្នងការមួយរូបដ៏ជោគជ័យ។ ការិយាល័យសិទ្ធិមនុស្ស អ.ស.ប ទន្ទឹងរង់ចាំទទួលស្វាគមន៍លោកស្រី និងបំពេញការងារក្រោមការដឹកនាំរបស់លោកស្រីនៅក្នុងភារកិច្ចលើកស្ទួយ និងការពារសិទ្ធិមនុស្សទាំងអស់ សម្រាប់ជនគ្រប់រូប និងនៅគ្រប់ទីកន្លែង"។

លោកស្រី បាស្សេឡេ ទើបបញ្ចប់ការងារជាប្រធានាធិបតីនៃប្រទេស ស៊ីលី (ពីឆ្នាំ ២០០៦ ដល់ ឆ្នាំ ២០១០ និង ពីឆ្នាំ ២០១៤ ដល់ ឆ្នាំ ២០១៨)។ លោកស្រីគឺជានាយកប្រតិបត្តិដំបូងគេបង្អស់ របស់អង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UN-Women)  នៅក្នុងរយៈពេលពីឆ្នាំ ២០១០ ដល់ ឆ្នាំ ២០១៣។ លោកស្រីក៏ធ្លាប់បម្រើការងារជារដ្ឋមន្ត្រីក្រសួងការពារជាតិ និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល នៃប្រទេសស៊ីលី ផងដែរ។ ថ្ងៃនេះ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តការជ្រើសតាំងលោកស្រី បាស្សេឡេ បន្ទាប់ពីគាត់ត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ សម្រាប់តំណែងជាឧត្តមស្នងការ ក្នុងអណត្តិរយៈពេល ៤ ឆ្នាំ។

លោកស្រី មីស្សែល បាស្សេឡេ នឹងក្លាយជាឧត្តមស្នងការ ទី ៧ គិតចាប់តាំងពីការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៩៣។ លោក ហ្សេអ៊ីដ រ៉ាអាដ អាល់ ហ៊ូសសេន បានចូលកាន់តំណែងតាំងពីថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០១៤។ ឧត្តមស្នងការមុនៗមានដូចជា៖ លោក ចូសេ អាយ៉ាឡា ឡាស់សូ (១៩៩៤-១៩៩៧); លោកស្រី ម៉ារី រ៉ូប៊ីនសុន (១៩៩៧-២០០២); លោក សឺជីអូរ វីរ៉ា ឌី មេឡូ (២០០២-២០០៣); លោកស្រី ឡួរីស អាបួរ (២០០៤-២០០៨); និង លោកស្រី ណាវី ភីឡៃ (២០០៨-២០១៤)។

ចប់

*ការិយាល័យសិទ្ធិមនុស្ស អ.ស.ប មានបុគ្គលិក ប្រមាណ ១.៣០០ នាក់ និងសហការជាមួយមន្ត្រីសិទ្ធិមនុស្ស ប្រមាណ ៧០០ នាក់ ដែលមានបម្រើការនៅក្នុងការិយាល័យបេសកកម្មសន្តិភាព ឬការិយាល័យនយោបាយរបស់ អ.ស.ប។ សរុបមក យើងមានវត្តមាននៅក្នុង ៦៧ ប្រទេស ជុំវិញពិភពលោក ដោយមានទីស្នាក់ការកណ្ដាលរបស់យើងនៅ ទីក្រុងហ្សឺណែវ ប្រទេសស្វីស។*

សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗសូមទាក់ទង៖ លោកស្រី *Ravina Shamdasani* តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩១៦៩ ឬ អ៊ីមែល៖ *rshamdasani@ohchr.org*) ឬ លោកស្រី *Liz Throssell* តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៤៦៦ ឬ អ៊ីមែល៖ *ethrossell@ohchr.org*) ក្នុងទីក្រុងហ្សឺណែវ ឬ លោក *Fred Kirungi* តាមរយៈអ៊ីមែល៖ *kirungi@un.org* នៅទីក្រុងញ៉ូវយ៉ក។

*ដើម្បីស្វែងយល់បន្ថែមអំពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស សូមចូលទៅកាន់៖ http://www.ohchr.org*

*ឆ្នាំ២០១៨ នេះ គឺជា**ខួបលើកទី៧០ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស** ដែលអង្គការសហប្រជាជាតិបាន អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្ដីប្រកាសជាសកលនេះជាប់លំដាប់ថ្នាក់ពិភពលោក ផ្នែកខាងអត្ថបទដែលត្រូវបានបកប្រែជា ៥០០ ភាសា ដោយផ្អែកលើគោលការណ៍គ្រឹះដែលថា "មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពខាងសេចក្ដីថ្លៃថ្នូរនិងសិទ្ធិ"។ គោលការណ៍គ្រឹះនេះ ស្ថិតនៅជាមួយមនុស្សគ្រប់រូប ជារៀងរាល់ថ្ងៃ។ ដើម្បីគោរពខួបលើកទី៧០ នៃឯកសារដែលមានឥទ្ធិពលដ៏វិសេសវិសាលនេះ និងដើម្បីរក្សាគោលការណ៍នេះកុំឲ្យបាត់បង់ យើងសូមស្នើឲ្យមនុស្សគ្រប់រូបនៅលើពិភពលោក **ក្រោកឈរឡើងដើម្បីសិទ្ធិមនុស្ស៖***

*www.standup4humanrights.org.*

*សូមថេក និងចែករំលែកតាម ទ្វីតធ័រ៖* @UNHumanRights *និងតាម ហ្វេសប៊ុក៖* unitednationshumanrights